


133

ទ្រ-៣៩-៣ ៥៤៩

ARCHIVES NATIONALES
REGIE DU DEPOT LEGAL

# រឿងពលឯកខ្មែរ ១

ជារឿងបុរាណសាស្ត្រស៊ីករឹត

អាចារ្យ

វ៉ង់-ឈឹន

នៅឃុំលេខ ៤ ក្រុងភ្នំពេញ

បានរៀបរៀង

ARCHIVES NATIONALES
COTE
B.107.1258 82

ការផ្សាយរបស់

បណ្ណាគារ

សេង-លី

លេខ ៧ មហាវិថីមិសត៍ ក្រុងភ្នំពេញ

នៅមុខស្ថានីយ៍អយស្ម័យយាន

បោះពុម្ព ៣០០០ ច្បាប់

ព.ស ២៤៩៥, គ.ស. ១៩៥២

ទុកសិទ្ធិ

# អារម្ភកថា

រឿងពលឯកកុមារនេះ ដែលបានគង់វង់មកដល់សព្វថ្ងៃនេះ ដោយសារខ្ញុំបានមើលពីក្មេងនៅវត្តលាំងកំពូល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ, ខ្ញុំក៏បានចាំរឿងនោះរហូតមកដល់ឥឡូវនេះ កាលដែលខ្ញុំមើលគឺជាសាស្ត្រាស្លឹករឹតគេតែងជាបទ កាកគតិនឹងបទព្រហ្មគិតជាដើម, ឥឡូវនេះខ្ញុំយកមកតែងជាបទពាក្យប្រាំពីរ, កាលដែលខ្ញុំមើលអាយុ ១៣ ឆ្នាំ ព.ស.២៤៥៩ គ.ស. ១៩១៦ មកដល់អាយុ ៤៩ ឆ្នាំ ព.ស. ២៤៩៥ គ ស.១៩៥២ នេះ, ខ្ញុំក៏តែងរឿងពលឯកនេះឡើងធ្វើជាសៀវភៅពីរក្បាលគឺទី ១ នឹងទី ២ ព្រោះកុំឲ្យក្រាស់ពេក, ប្រាថ្នាទុកឲ្យខេមរជនបានអានបានមើលនឹងបានប្រើយករឿងនេះ ទុកជាទីមនោរម្យដល់លោកអានទាំងឡាយតទៅ ។

ខ្ញុំបាទតែងផ្ទួនរឿងនេះចប់ហើយ ក៏បានប្រគល់ឲ្យទៅថៅកែអាំង ហួតផុះលេខ....ខាងជើងផ្សារសួនថ្មី វិថីវីរជង នឹងថៅកែ សេង-លី មហាវិថីមិសត៌ភ្នំពេញ ឲ្យបោះផ្សាយ គាត់ក៏មានសេចក្ដីរីករាយត្រេកអរណាស់ដោយបានរឿងបុរាណប្លែកល្អ, ខ្ញុំក៏មានចិត្តត្រេកអរថាមុខជានឹងបានរឿងពលឯកនេះ ចូលជ្រកក្នុងសន្ដាននៃលោកអ្នកអានទាំងឡាយ គ្រាន់ជាទីមនោរម្យពុំខាន ។

ទីបំផុតនេះ ខ្ញុំសូមអភ័យទោសអំពីសំណាក់នៃលោកអ្នកជាកង បណ្ឌិតទាំងឡាយ ក្រែងខ្ញុំតែងឃ្លៀងឃ្លាតសម្ផស្សពាក្យ សូមកុំនិន្ទ

ជាអ្វី បើឃើញខុសឃ្លៀងឃ្លាតត្រង់ណា សូមដម្រង់ត្រង់នោះឲ្យបានផង ព្រោះខ្ញុំតែងប្រញាប់ប្រសាន់ពេក សៀវភៅភាគទី ១ នេះតែងតែមួយអាទិត្យប៉ុណ្ណោះឡើយ ។

# រឿងពលឯក

ខ្ញុំសូមថ្វាថ្លែងតែងជាកាព្យ- ប្រាំពីរពាក្យកបរៀងដល់ចប់
លោកអ្នកឯណាដែលប្រសប់- អានមើលដល់ចប់ដឹងសេចក្ដី ។
រឿងនេះជារឿងបុរាណចាស់. មិនមែនជារឿងកើតថ្មី ៗ
លោកអ្នកបេះអានទោះប្រុសស្រី ចាស់ក្ដីក្មេងក្ដីគិតផងចុះ ។
ដំណាលកាលរឿងចៅពលឯក ក្រីក្រពន់ពេកលំបាកស្មោះ
មាតាបិតាទ័លទាំងអស់ ទាំងទ្រព្យរបស់ក៏គ្មានអ្វី ។
នៅផ្ទះមួយតូចក្នុងព្រៃស្ងាត់ ញាតិសួរសត្វទារទោចរ
ទីទុយមៀមមុំយំសព្វថ្ងៃ តែពីរនាក់ប្ដីនឹងប្រពន្ធ ។
លង្ហលុះវេលាព្រឹកមួយ ដេកលក់ជាមួយស្វាមីលន់
សុបិននិមិត្តស្រស់ស្រីតន់ ឃើញតាចាស់កាន់កែវល្អក្រៃ ។
ដើរចូលជិតមកនាងវរលក្ខណ៍ យកកែវមកដាក់លើបាតដៃ
ដូចផ្លែពលឯកល្អពេកក្រៃ ដាក់ទៅលើដៃថយចេញទៅ ។
លុះនាងភ្ញាភ្ញាក់ឡើងកាលណា ជិតាដាស់ប្ដីនាងស្រីពៅ
ថាអ្នកស្វាមីក្រោកឡើងក្លូវ កុំនៅសម្រាន្តឲ្យយូរពេក ។
ជួយកាត់សប្ដិខ្ញុំប្លែកឥម៉្លេះ សប្ដិនេះហៅពេញជាចម្លែក
តាចាស់កាន់កែវក្រហមថ្លែក ដូចផ្លែពលឯកដាក់លើដៃ ។
ស្រាប់តែខ្ញុំភ្ញាក់រកពុំឃើញ ស្ដាយហើយសែនស្ដាយឥតឧបម័យ

សប្តិនេះដូចម្តេចណាប្រុសថ្លៃ　　អ្នកជួយលកលៃកាត់បន្តិច ៗ
ប្អូនអើយសប្តិនេះល្អណាស់ណា　　បូរាណចារ្យលោកប្រាប់
មុខជាបានកូនប្រុសសម្រេច　　បណ្តូលបណ្តាច់មានបុណ្យផង ៗ
លង់លុះយូរជាអង្វែងទៅ　　ឯស្រស់ស្រីពៅនាងនួនល្អង
នាងមានគភ៌គ្រប់ខែហើយហោង　　នួនល្អងថ្នាក់ថ្នមមិនឲ្យអាក់ ៗ
លុះគ្រប់ខែដប់ប្រសប់បុះ　　ប្រសូតកូនប្រុសល្អសមស័ក្តិ
យកតាមនិមិត្តទាន់មកដាក់　　វរលក្ខណ៍ឲ្យឈ្មោះចៅពលឯក ៗ
លង់លុះកន្ទង់ឆ្នាំមួយពីរ　　នារីនាងមានគភ៌ឥតប្លែក
ប្រសូតកូនប្រុសល្អបំប្លែក　　ឲ្យនាមយ៉ាន់ឯកអនុជា ៗ
ឯបុរសប្តីនឹងប្រពន្ធ　　ទៀយហត់ពេកលន់ពល់វេលា
ព្រួយតែនឹងរកស្បៀងអាហារ　　លំបាកវេទនាព្រោះអត់ឃ្លាន ៗ
រីឯកុមារទាំងពីរនាក់　　ឪពុកធ្វើជួយម្នាក់បាន
ដើរបាញ់បក្សីក្នុងសំសាន　　ឆ្ងាយចេញពីស្ថានផ្ទះអាត្មា ៗ
ចេញទៅត្រឡប់វិញរាល់ថ្ងៃ　　ពុំដែលខានទេពីរកុមារ
លុះដល់ថ្ងៃក្រោយមួយទៀតណា　　ចូលក្នុងព្រៃគ្រាលេងសប្បាយ ៗ
ចូលក្នុងព្រៃជ្រៅស្ងាត់ត្រឈឹង　　ប្រាប់ថាព្រលឹងមាសបងអើយ
មើលផ្លែពលឯកល្អម៉្លេះហើយ　　រលោងស្មើស្រក់ទឹកចុះមក ៗ
ចាំដល់បងធំរកប្រពន្ធ　　ដូចផ្លែពលឯកបានបង់យក

បើមិនបានដូចទេពនូក    ម្ដាយរកបង់រត់ចោលគាត់ហើយ ។
និយាយនឹងប្អូនពាក្យប៉ុណ្ណឹង    ប្អូនគិតជញ្ញឹងឥតមានស្បើយ
លុះដល់មកផ្ទះប្រាប់ម្ដាយហើយ    ថាអ្នកម្ដាយអើយបងគាត់ថា ។
តែដល់គាត់ធំរកប្រពន្ធ    រូបល្អលើសលន់ទើបបានការ
ដូចផ្លែពលឯកលើព្រឹក្សា    មិនបានកាលណាគាត់រត់ចេញ ។
ម្ដាយពុកូនតូចប្រាប់ដូច្នោះ    ខឹងញ័រគ្រន់ពោះដើរបណ្ដេញ
អាឯងកុំនៅចូលនឹងអញ    បើអាស្រឡាញ់អារកចុះ ។
អញរកមិនបានល្អចំឡែក    ដូចផ្លែពលឯកទេកូនប្រុស
បើឯងរកបានទៅរកចុះ    មិនថាទេប្រុសថ្លៃមាសម្ដាយ ។
អ្នកណាចិត្តធំមិនស្ដាប់អញ    ចូរបាចយចេញអញមិនស្ដាយ
កុំនៅឲ្យអញក្ដៅក្រហាយ    កូនមិនស្ដាប់ម្ដាយចេញឲ្យឆាប់ ។
ឯកុមារជាបងនោះ    ពុម្ដាយបន្ទុះបន្ទោសសាប
គាត់គាំចិត្តព្រោះចេញប្រញាប់    ក្រឡាប់វិលវៃចូលព្រៃជ្រៅ ។
ឯប្អូនឃើញបងរត់ទៅច្បាស់    អាល័យបងណាស់រត់តាមទៅ
ទាំងបងត្រង់ពាក់កណ្ដាលផ្លូវ    បណ្ដើរគ្នាទៅគាត់ព្រឹក្សា ។
លុះពេលថ្ងៃល្ងាចមេឃស្រទំ    ពពកបាំងគុំព្រះសុរិយា
កុមារទាំងពីរខំយាត្រា    លេចក់លហើយណាចូលព្រៃធំ ។
ថ្ងៃនោះជួនជាមេឃងងិត    ពពកបាំងបិទងងិតគ្នំ

ផ្គរសព្ទទិសាព្រមៗ　　កុមារតូចយំរកម្ដាយ ។
ទំនួញថាៈ ! អ្នកម្ដាយអើយ　　កូនឃ្លាតឆ្ងាយហើយពីអ្នកម្ដាយ
ភ្លៀងរងាខ្លាំងញ័រអស់កាយ　　ម៉េះសមអ្នកម្ដាយមើលផ្លូវកូន ។
ឯបងព្រួយប្អូនយំសោយសោក　　វិយោគក្នុងព្រៃឈឹងស្ងាត់សូន្យ
ខ្លាចផ្សារក្នុងចិត្តអាណិតប្អូន　　លោមថាមាសស្ងួនកុំយំស្រែក ។
ចាំបងពួតភ្លើងបង្កាត់ឲ្យ　　ប្អូនអើយកុំឲ្យរងាពេក
បងធ្វើដំរិឲ្យប្អូនដេក　　កុំយំខ្លាំងពេកអាណិតបង ។
លួងប្អូនហើយស្រេចកាច់មែកឈើ　　ដាក់ពីខាងលើស្រេចជាម្ដង
ពួតភ្លើងបង្កាត់នេះបានហោង　　កំដៅឆ្អឹងខ្នងសព្វរៀងកាយ ។
យប់ជ្រៅបន្តិចភ្លៀងក៏រាំង　　កុមារទាំងពីរសុខសប្បាយ
បានភ្លើងនេះខ្លាំងកំដៅកាយ　　ភ្លេចនឹកដល់ម្ដាយបានដេកលក់ ។
កុមារទាំងពីរអស់កំឡាំង　　ស្មារតីភាន់កាំងសូរស្រមុក
បានភ្លើងក្ដៅៗនេះគគុក　　គគុលដេកលក់ដរាបព្រឹក ។
ភ្ញាក់ឡើងគិតគ្នាធ្វើអន្ទាក់　　វេញខ្សែពីរនាក់ឲ្យសន្ធឹក
ធ្វើជាអន្ទាក់ដាក់សត្វម្រឹគ　　លុះដល់ពេលព្រឹកយើងទៅមើល ។
កុមារទាំងពីរកាប់ឃ្លាយមក　　សកយកសម្បកបានទៅហាល
ហើយសកយកទាំងសម្បកព្រាល　　អន្ទងដំដាលទន់ល្ងន់ល្ងាស ។
វេញខ្សែរួចហើយធ្វើអន្ទាក់　　បានយកទៅដាក់ច្រើនពេញពាស

ស្រាស់ជាប៉ែក ៗ មែកឈើក្រាស់   អន្ទាក់ពេញពាសអស់តាំងព្រៃ ។
រីឯពួកម្រឹគឈ្លូសរមាំង   ជ្រូកក្ដាន់ប្រើសព្រាយទន្សាយក្ដី
ចូលក្នុងអន្ទាក់ជាប់ច្រើនក្រៃ   ក្សិណក្ស័យជីវិតឥតគណនា ។
លុះដល់ព្រឹកព្រាងអរុណោទ័យ   កុមារពីរថ្ងៃបរយាត្រា
ទៅមើលអន្ទាក់ដាក់នៅនា   ជងអញ្ញាក់ច្រើនក្រាស់ក្រៃ ។
ឃើញពួកសត្វម្រឹគជាប់គគោក   ស្លាប់ក្នុងអន្ទាក់នោះឯងនៃ
នាំគ្នាកាប់ស្នែងសែងវិលវៃ   មកដល់នាពួកខ្ទែងខ្លួន ។
ធ្វើជាចង្អើរមួយយ៉ាងធំ   ដុតភ្លើងដង្គុំធេះម៉ាមួន
លើកសត្វធំ ៗ ដាក់សំនួន   ចំប្រឹងថៃរធួនង្អើរសាច់នោះ ។
លុះង្អើរឆ្អិនស្រេចពីរកុមារ   បានបរិភោគគ្នាឆ្អែតពេញពោះ
សាច់ង្អើរច្រើនពេកស៊ីពុំអស់   លើកសាច់ង្អើរនោះទេរទុកទៅ ។
រីឯសាច់ង្អើរក្លិនឈ្ងុយឈ្ងប់   ខ្យល់បក់ត្រឡប់សព្វទិសា
ធុំក្លិនដល់ក្រុងអសុរា   ជាស្ដេចយក្សានៅក្នុងព្រៃ ។
យក្សនោះមានឫទ្ធិអំណាចខ្លាំង   មិនហ៊ានតតាំងនឹងគេដៃ
បាក់បបខ្ទបខ្ទាចព្រះបារមី   ក្រុងអសុរីមានបុណ្យខ្លាំង ។
ព្រោះមានសម្បត្តិបួនប្រការ   ឆ្នាំងឆ្អិនឯងណាកន្ទ្រងបោយ
ខ្សែចងឯងផងធំបណ្ដោយ   ដេញវាយពីក្រោយដកបកប ។
ស្ដេចមានសម្បត្តិបួនប្រការ   គ្មានយក្សឯណាមកផ្ទឹមប្រៀប

យានទៅត្រង់ណាសឹងធុនក្រាប សិរសាទន់ទាបរាបដល់ដី ៗ
មិនខ្លាចតែត្រឹមយក្សប្រុស ៗ ខ្លាចនោះរហូតយក្សស្រី ៗ
ដំណើរស្តេចយានព្រះបក្រី ទៅចំយក្សស្រីភ័យបំប្រប់ ៗ
ហេតុតែគ្នាខ្លាចអំណាចពេក ដោយបុទ្ធបារមីខ្លាំងលើសលន់
ស្តេចយក្សត្រូវខាតបង់ទ្រព្យធន ឲ្យខ្លួនអាប់អន់ធនបានគេ ៗ
វេលាជុំក្លិនសាប់ផ្អើរនោះ ពាល់ត្រូវច្រមុះយក្សរិះរេ
នរណាផ្អើរសាប់ឈ្ងុយម្ល៉េះទេ ថាមេអញអត់ទ្រាំពុំបាន ៗ
គិតស្រេចស្តេចចាប់ដំបងពេជ្រ ហោះហិចកណ្ដាលអាកាសស្ថាន
ផ្ទុកផ្ទោះសំដៅទៅហេមពាន្ដ យក្សចុះឈរឈម នឈប់រោ ៗ
យក្សអើតផ្អៀងផ្អងរេងើបងើយ ទៅមុខថយក្រោយសព្វទិសា
ទៀបទីបផ្អើរកុមារ យក្សឃើញហើយណាក៏លាន់មាត់ ៗ
ថាឃើអើ ! នេះពេញមានលាភ ជាមហាភក្សធំក្នុងព្រៃស្ងាត់
សាប់ផ្អើរស្រោប់ ៗ មានគ្រប់សព្វ ស៊ីឈ្ងុយសម្លុយម៉ាត់ឲ្យដឹងចិត្ត ៗ
យក្សពមតាំងក្បាលពមតាំងជើង ឈ្ងុយសម្លុយរុញឡើងទៅក្នុងមាត់
ទំពាគ្រុប ៗ ដូចគេកាត់ អស់ពីក្នុងមាត់ថែមមួយទៀត ៗ
ឯកុមារបង់ក៏មិននៅ ត្រឹកព្រានដើរទៅមើលអន្ទាក់
រីឯប្អូនតូចនៅតែម្នាក់ អង្គុយមើលយក្សស៊ីសាប់ផ្អើរ ៗ
យក្សស៊ីរួចហើយហិចហោះទៅ ទីស្ថានលំនៅប្រាង្គណ៍ប្រសើរ

ឯកុមារប្អូនមើលសាច់ឆ្អើរ លើឆ្អើយក្រសុំអស់គ្មានសល់ ។
ឯកុមារបងត្រឡប់វិញ កន្ទោះខ្វល់ខ្វាញ់ឃ្លានខ្លាយខ្វល់
ប្រញាប់រូតរះឡើងឆាប់ដល់ បរិភោគស្កុបស្កល់សាច់ឆ្អើរនោះ ។
មកដល់កាលណាក្រឡេកមើល សាច់លើចង្អើរលើនអស់
សាច់ឆ្អើរទៅណានែប្អូនប្រុស ម្ដេចអស់ប្អូនប្រាប់បងឲ្យដឹង ។
ប្អូនក៏ចចារប្រាប់បងខ្ញី មិនដឹងជាអ្វីបងកុំខឹង
ប្អូនក័យពេកក្ដាត់ថាត់ព្រលឹង សត្វទឹងចង្កូមពេមបង្កា ។
ចុះពីអាកាសកាន់ដំបង អង្គុយប្រហោងស៊ីមំសា
មិនមានកោតខ្លាចអាចថេស្ដា ស៊ីរួចយាត្រាហិចហោះទៅ ។
ប្អូនអីយបងពុចាស់លោកថា មានពុកបង្កាចង្កូមកូវ
ពុកមាត់ស្រមាមពេមស្រមូវ ចាស់ ៗ លោកហៅថាយក្ស ។
យក្សនោះចិត្តវាគក្រក់ណាស់ លោភៅទោសោមហោណា
វាល្អួចវាធក់ឥតមេត្តា ទឹងហើយយក្សណាមាសបង ។
ប្អូនពុបងប្រាប់សត្វសេចក្ដី ដឹងហើយអនក័យក៏តខ្លាចផង
សារសព្វដំណើរដោយដើមទង សត្វក្រប់ហើយហោងប្អូនសុខចិត្ត ។
ឯបងនាំប្អូនចូលព្រៃជ្រៅ ដើររកកាប់ផ្ដៅប្រិនក្រៃពិត
នាំគ្នាពុះជ្រៀកឲ្យល្អិត ៗ ទើបយកមកបិតទុកធ្វើជុប ។
តាំងពីកុមារខំប្រឹងធ្វើ បងចាក់ខាងលើប្អូនប្រឹងមុច

ខំប្រឹងហូតផ្តៅខាងគង់ដុច    ប្រឹងទាក់ប្រឹងមុចទាល់តែហើយ
កុមារធ្វើដុចធំក្រៃលែង    ធំហើយវៀនវែងឥតធ្ងឹមឡើយ
ដាក់ចោលនៅស្មៀមធ្វើព្រងើយ    សម្រេចដល់ហើយផ្តៅដប់បាច់
រឿងនេះខ្ញុំស្ទុះឈប់ចចារ    ថ្លែងពីអសុរយក្សបន្តិច
ដែលវាធ្លាប់មកបានស៊ីសាច់    វានឹកមិនក្រេបមួយវេលា
រីឯស្តេចយក្សដល់ពេលឃ្លាន    នឹកដល់ហោមពាន្តអរញ្ញា
ចាប់ដំបងខ្ចីចរយាត្រា    ហោះលឿនអស្ចារ្យដល់កន្លែង
ស្រេចហើយយក្សបរកុះសំដៅ    ដល់អង្គុយនៅធ្វើចំខែង
ហៅទៅកុមារជាព្រះស្តែង    កុមារតូចឯងធ្វើអ្វីអេះ
កុមារទាំងពីរតបឆ្លើយជូន    តនឹងយក្សផ្គងដោយតម្រិះ
ថាតាអើយតាខ្ញុំធ្វើនេះ    ហៅដុចខ្ញុំរះរកដាក់សត្វ
រមាសរមាំងប្រើសទន្សាយ    ល្មូសទ្រាយប្រមារខ្លាដើរកាត់
ឲ្យតែចូលដុចជាប់គ្រប់សត្វ    តែហ៊ានបោលកាត់ជាប់ដុចខ្ញុំ
យក្សថាទែទៅដុចប៉ើងរ៉ុង    ម្តេចអួតថាជាប់សត្វធំ ៗ
ប៉ើងរ៉ុងដូច្នេះទៅអើយកុំ    មិនជាប់សត្វធំទេណាចៅ
ឯសត្វអស់នោះវាខ្លាំងណាស់    វាប៉ុនប្រមាសណាស់ពេកក្រូ
បើចៅមិនជឿក្នាល់ឥឡូវ    តាត្បុលចូលទៅល្បងដុចមើល
ប៉ុណ្ណឹងបើតារើពុំរួច    ចៅតិះដៀលចុះថាតាព្រិល

ចាស់អ៊ីអ៊ំនួតអួតឯងឆើល　　ចាស់ព្រើលមិនគិតប្រយោគរូប
បើតាបម្រាសដុចចៅផាច់　　តើចៅសម្រេចឲ្យអ៊ីហូប
ថាឲ្យប្រាកដចំពោះរូប　　ឲ្យម្ហូបបុះចៅឲ្យអ៊ីតា　　ៗ
កុមារពីរស្ដាប់យក្សអធិប្បាយ　　កុមារដោះស្រាយដោយប្រាជ្ញា
ខ្ញុំមានសាច់ផ្អើរជូនពីសា　　ចូលដុចចុះណាលោកតាអើយ　　ៗ
យក្សប៉ូលគន្ធុដុចកក្រលទៅមុខ　　ចូលហួសជ្រុលស៊ុនផុតដើងហើយ
បម្រាសពុំរួចស្រែកយ៉ើយ ៗ　　ថាឱចៅអើយអាណិតទៅ　　ៗ
កុមារទាំងពីរគាន់ផ្ដាំចាំ　　ខ្ញុំប្រឹងថែទាំអគ្គ័យនៅ
ដាច់ដួសដាច់ដួសថែមទៀតទៅ　　រឹងខ្លួនរឹងភ្លៅរើពុំរួច　　ៗ
កុមារទាំងពីរថាតាអើយ　　ម្ដេចឡើយថ្ងៃមុនតាហ៊ានលួច
ស៊ីប្រិទមឹ៍ង ៗ រើពុំរួច　　ម្ដេចតាហ៊ានលួចសាច់ផ្អើរខ្ញុំ　　ៗ
កុមារតូចទាញចាប់ពុកមាត់　　យកទៅបងព័ទ្ធនឹងឈើធំ
ទាញរឹតយ៉ាងតឹងយក្សស្រែកយំ　　ថាចៅកុំ ៗ អាណិតតា　　ៗ
កុំរឹតខ្លាំងពេកឈឺតាណាស់　　អាណិតតាចាស់ណាចៅណា
របោចរបេះពុកចង្កា　　ចៅកុំលេងតាធ្ងន់ដៃពេក　　ៗ
កុមារបងចាក់ចង្កេះយក្ស　　បែបដូចជាភ្ញាក់យកប្រឹងស្រែក
កុមារប្អូនយកដៃរុកក្លៀក　　យក្សស្រែកស្ទើរបែកព្រៃព្រឹក្សា　　ៗ
យក្សអង្វរហើយអង្វរទៀត　　ល្មមហើយលោកចៅអាណិតតា

ដាច់ខ្យល់ឥឡូវទៅហើយណា  អាណិតមេត្តាតាសូមសុំ  ៗ
ចៅអើយ ៗ ចៅសូមមេត្តា  ចុកណែនខ្លោចផ្សាទុក្ខក្រម
ឈឺអស់សព្វសាច់ដូចគេដំ  ចៅអើយតាសុំអត់ទោសតា  ៗ
បើចៅលែងតាក្នុងពេលនេះ  តាឲ្យទ្រព្យថ្លៃជូនប្រការ
ខ្សែចងដំបងវាយឯងក៏  កន្សែងហ្លោយណាថ្នាំងផ្ទួនឯង  ៗ
កុមារថាបើពាក្យតាពិត  ដូចជាតាគិតខ្ញុំនឹងលែង
ខ្សែចងដំបងនឹងកន្សែង  ទាំងថ្នាំងផ្ទួនឯងខ្ញុំលែងភ្លាម  ៗ
ចៅអើយពាក្យតាថាប្រាកដ  ចៅលែងតាចុះកុំទីមទាម
តាមតាទៅចុះតាជូនភ្លាម  មិនឲ្យទាក់ទាមទេណាចៅ  ៗ
កុមារទាំងពីរកាត់ផ្តៅស្រេច  អស់មួយរំពេចគ្មានសល់នៅ
យក្សក្រោកអង្គុយឡើងប្រឹងរូ  ថាចៅអើយចៅតាបានរស់  ៗ
ឥឡូវតាផ្ដាំចាំឲ្យជាក់  ចៅទៅស្រុកយក្សទិសឯណា៖
អញ្ជើញទៅក្រោយតាមតាចុះ  ស្រុកនោះមិនឆ្ងាយប៉ុន្មានឡើយ  ៗ
បីថ្ងៃនៅខាងទិសឦសាន  ចៅមុខជាបានដល់តាហើយ
តាលាទៅមុនចៅទៅក្រោយ  តាធ្វើផ្លូវឲ្យចៅស្រួលដើរ  ៗ
យក្សនោះចេញផុតពីកុមារ  ខ្ញីឃ្នាតយាត្រាដកដើមឈើ
ខំត្រាយត្រួសផ្លូវឲ្យចៅដើរ  យក្សខំប្រឹងធ្វើដល់នគរ  ៗ
លង់លុះដល់ព្រឹកព្រះសុរិយា  ទាំងពីរកុមារយាត្រាចរ

ក្នុងព្រៃហេមរាព្រឹក្សាក៏ សំដៅនគរក្រុងអសុរី ។
ឃើញព្រៃព្រឹក្សាដុះជាជួរ មុខគួរឲ្យមើលលេងប្រុសថ្លៃ
ស្រឡិតដុះជិតដើមស្រឡី ធ្នេញត្រីដុះជិតជិតដើមត្រាច ។
គគីរដុះនែបអែបគគិត ឈើទាលដុះជិតក្រពេញពាដ
ស្រឡៅស្រល្វត់ខ្ពស់បំញ្ចាប កញ្ជើបាយដាបជិតមាក់ដោក ។
មាក់ប្រាងដុះជិតជិតមាក់ប្រេង ដើមបេងដុះបៀតដើមកកោះ
លំពាន់ពារវ័ណ្ណទឹងលំពោះ បន្ទន់ត្រស់ដុះជិតដើមក្រឹស្នា ។
ប្អូនអឺយប្អូនមើលដើមក្រូចក្រាយ ដាជួររៀងរាយណាកែវណា
ឈើប្រឹនពណ៌ណាស់ក្នុងព្រឹក្សា មិនឈ្នះពណ៌នាទេប្រុសបង ។
កុមារទាំងពីរខំប្រឹងត្រាច់ បីថ្ងៃសម្រេចដូចបំណង
ដល់ស្រុកយក្សាស្រេចហើយហោង បរបូលជាមួងក្នុងវាំងវៃ ។
ស្ដេចយក្សត្រុថាកុមារមក ខំស្ទុះងើបក្រោកចេញពីក្នុង
ទទួលកុមារទាំងពីរពង្ស ស្ដេចរៀបប្រៀបប្រុងគ្មានខ្វះអ្វី ។
ក្រាលពូកព្រៃព្រំបៀមបំផង រនាំងវាំងននដូចម្ដេចក្ដី
កន្ទេលខ្នល់ខ្នើយល្អថ្មីៗ បក្រិចឲ្យក្រាលគ្រែសយនា ។
អញ្ជើញកុមារទាំងពីរពង្ស ឲ្យចូលទៅស្រង់រសគន្ធា
លំអិតខ្ទឹមបន្ទន់ប្រស់ក្រឹស្នា ពារវង់ថ្វាក្រអូបសាយ ។
ស្រង់ស្រេចស្ដេចឲ្យផ្លាស់ព្រះពស្ដ្រ អង្គកុមារាទាំងពីរកាយ

ស្តេចឲ្យអញ្ជើញក្រយាបាយ　ភោជនទាំងឡាយពេញត្រៀបត្រា ៗ
បរិភោគហើយស្រេចស្តេចឲ្យជុំ　លើតូកព្រែព្រំទីសុវណ្ណា
ដោយអស់កំឡាំងព្រះកាយា　និទ្រាលក់លង់ពុំដឹងប្រាណ ៗ
ទាំងពីរកុមារក្រោកនិទ្រា　ចុះចាកសុវណ្ណមាសកល្យាណ
ពួកយក្សគង់គាល់ក្នុងរាជស្ថាន　ស្តេចយក្សក៏មានពាក្យពោលថា ៗ
ហៃបាទាំងពីរបងនឹងប្អូន　យើងសុំជាកូនណាប្រុសណា
កុំកូនប្រកែកនឹងបិតា　បានរសជីវ៉ពីកូនឯង ៗ
ឪពុកដូចបានកើតម្តងទៀត　បារុយប្រាកដពិតជាក់ស្តែង
ឪពុកកុំបានតែបាឯង　ម្ទះសមចម្បែងស្លាប់បង់ម្យៀត ៗ
គ្មានអ្នកណាដឹងពោលក្នុងព្រៃ　អាសោចពេកក្រៃដូចសត្វធាតុ
ពេលនេះដូចជាកើតម្តងទៀត　កុំអីបង់ជាតិបង់ជីវ៉ ៗ
ស្តេចមានបន្ទូលរំលឹកគុណ　កុមារតូបតន់ទាំងទ្វេហា
សរសើររូបស្រេចឲ្យចារថា　ឲ្យប្រុសកុមារបានសោយរាជ្យ ៗ
ពេលនោះស្តេចទ្រង់ប្រទានឲ្យ　កន្សែងបក់បោយនោះឯងអាច
ឆ្មាំងផ្អិនឯងធំដោយអំណាច　ខ្សែចងដំបងវ៉ាយឯងណា ៗ
ទាំងពីរកុមារលើកហត្ថឡើង　ទទួលពរពីធមិបិតា
ទទួលព្រមទាំងទ្រព្យថ្លៃថ្លា　ទាំងបួនប្រការបិតាឲ្យ ៗ
ឯក្រុងអសុរីសួរនាមបុត្រ　ឈ្មោះអ្នកប្រាកដប្រាប់កុំភ្លោយ

ឈ្មោះអ្វីទៅក៏ណាកូនអើយ　ក្រែងដល់ថ្ងៃក្រោយមានទុក្ខភ័យ ។
ឪពុកលើកពលទៅជួយណា　ក្រែងកូនមានការអាសន្នអ្វី
ពួកពលបិតាច្រើនក្រាសក្រៃ　កុំឲ្យគិតភ័យតទៅមុខ ។
កុមារលើកហត្ថពីរទូលថា　បពិត្របិតាចូរចាំទុក
ដំណាពីនេះតទៅមុខ　ខ្ញុំនាមឈ្មោះថាចៅពលឯក ។
ឯប្អូនខ្ញុំនោះឈ្មោះអនុជ　បាននាមពីមាតាបិតា
ឯនាមឈ្មោះទាំងពីរនេះណា　ចាំចុះបិតាកុំឲ្យភ្លេច ។
កូនសូមក្រាបទូលបិតាផង　នាមបិតាហៅឈ្មោះដូចម្ដេច
ដំណាទៅមុខក្រែងមានកិច្ច　រឿងរ៉ាវម្ដេច ៗ កូនបានដឹង ។
ឯនាមឈ្មោះយើងជាឪពុក　បារ៉ុយចាំទុកប្រុសព្រលឹង
យើងប្រាប់ឲ្យច្បាស់កត់ត្រាហ្នឹង　ចាំចុះព្រលឹងឈ្មោះបិតា ។
វិរុឡ្ហមាត្យក្រុងអសុរ　នាមអគ្គមហេសីស្រីចន្ទ្រា
បុត្រីនាងចន្ទបទុមា　ក្រុងព្រះសោមាពេជ្របុរី ។
ហៃបាទាំងពីរចាំឲ្យជាក់　ឪពុកប្រាប់អ្នកសព្វសេចក្ដី
ក្រែងដល់ខាងមុខបាមានភ័យ　ចូលមកបុរីប្រាប់បិតា ។
ទាំងពីរកុមារនឹងអសុរ　ប្រាប់សព្វសេចក្ដីគ្រប់ប្រការ
ទៅវិញទៅមកពីនាមា　ប្រាកដប្រជាគ្មានបន្ទោះ ។
កុមារទាំងពីរថ្វាយបង្គំ　បិតាមាតាព្រមទាំងអស់

បពិត្របិតានៅនេះចុះ　　កូនថ្វាយបង្គំលាសិនហើយ　ៗ
ក្រុងអស្សុរីព្ភូកូនលា　　ថ្លែងថាថ្លៃមាសឪពុកអើយ
ប្រុសកុំនៅយូរណាអ្នកអើយ　　ប្រុសអើយឆាប់វិលត្រឡប់ពា　ៗ
វេហាពីរកុមារចាឈប់សិន　　កុំអាលប្រញាប់ឆាប់យាត្រា
ចូលស្តាប់បណ្ដាំយើងបិតា　　គិតការដំណើរទៅទៀត　ៗ
ទ្រង់មានបន្ទូលនឹងមហេសី　　ថានៃស្រីថ្លៃជួយជួះផ្ទៀត
បងចង់គិតការបន្តិចទៀត　　កុំឲ្យផុតជាតិត្រកូលយើង　ៗ
ចន្ទបទុមាបុត្រីនេះ　　ផ្សំផ្គុំនឹងកូនឲ្យចុំច្រើន
ត្រងរាជ្យបូរីបានរុងរឿង　　លុះអស់ពីយើងទៅកាលណា　ៗ
បពិត្រស្វាមីម្ចាស់ខ្ញុំអើយ　　បន្ទូលត្រូវហើយរៀមជេដ្ឋា
បំណែកនាងចន្ទបទុមា　　ពីតាអាយុបានដប់ឆ្នាំ　ៗ
ប្រាំមួយវស្សាទៀតទើបគ្រប់　　ប្រសប់ចួបចប់តាមចំណាំ
គ្រប់ជាប្រាំមួយដណ្ដប់ឆ្នាំ　　ដាក់ផ្កាកូនយើងទៅទៀតបាន　ៗ
ពន្លកពន្លៃស្រីចំន្រ្ទា　　ថ្លៃថ្លានាងហៅកូនកល្យាណ
ចន្ទបទុមាពីកុង្ស្ថាន　　ឲ្យបានបុត្រាឃើញប្រាកដ　ៗ
ទ្រង់ត្រាស់ឲ្យហៅមកដល់ហើយ　　ថាហៃកូនឆ្នើយចូលតាមបទ
កុមារទាំងពីរនេះសន្ធ　　ប្រាកដជាបងកូនឯងហើយ　ៗ
ឲ្យធ្វើបបួនប្រាំមួយឆ្នាំ　　គប់តាមបណ្ដាំបិតាក្រោយ

ហួសពីនោះទៅអភិសេកឲ្យ    គ្រប់គ្រងបុរីរាជសេមា ៗ
ឥឡូវគ្រាន់តែផ្ដែផ្ដាំទុក    ចាំពាក្យឪពុកណាកូនណា
ព្រោះពុំទាន់គ្រប់ព្រះជន្មា    បិតាផ្សែផ្សំទុកជាមុន ៗ
ច័ន្ទបទុមានាងក្មេងណាស់    វរាជក្សត្រិយ៍ស្រីអៀនអន់
ក្នុងព្រះបិត្តាស្រឡាញ់លន់    មិនហ៊ានគយគន់ជាក់ក័ក្ដ្រា ៗ
ក្សត្រិយ៍លបទតបុងព្រះនេត្រ    មិនឲ្យដឹងហេតុដល់អ្នកណា
ឃើញទ្រង់អង្គព្រះកុមារា    ក្ដួលក្នុងឧរពាំរបំប្រប់ ៗ
ឯព្រះកុមារទតនាងជាក់    ដូចគេកន្ទ្រាក់ក្រ្តដួលដួប
ក្នុងចិត្តស្រឡាញ់នាងលើសលប់    ប៉ុន្តែប្រឹងផ្ទប់ធ្វើព្រងើយ ៗ
បិតាមាតាឲ្យពរថា    ឲ្យបានសុខាមូលគ្នាហើយ
គ្រងរាជសម្បត្តិទៅខាងក្រោយ    កុំឲ្យសត្រូវមកបៀតបាន ៗ
ក្រុងពេជ្របុរីមានអំណាច    នរណាក៏ខ្លាចមិនអាចហ៊ាន
សម្បត្តិទាំងបួនប្រការមាន    ប្រធាននគរកូនឯងហើយ ៗ
ឯកុមារប្អូនចាំឪពុក    នឹងគិតជាក់ទុកទៅខាងក្រោយ
គ្រប់ប្រាំមួយឆ្នាំបងឡើងសោយ    កុមារប្អូនឲ្យធ្វើឧបរាជ ៗ
ពលរេហ៍ទាំងអស់ជាចំណុះ    ឲ្យតាំងនៅចុះក្រោមអំណាច
ប្រាំមួយឆ្នាំទៀតបងសោយពង្ស    កូនប្អូនឧបរាជកាន់រេហ៍ពល ៗ
លុះចប់បណ្ដាំស្រេចហើយណា    អង្គព្រះកុមារនឹងខ្វាយខ្វល់

អាណិតក្សត្រិយ៍ស្រីនិមល ពុំដឹងកិច្ចកលដល់តិចឡើយ ។
បពិត្រតាំងទូទីស្នេហា មាតាបិតាម្ចាស់កូនអើយ
កូនថ្វាយបង្គំលាសិនហើយ ដល់ពេលខានក្រោយកូនវិលវិញ ។
ចន្ទបទុមាមាសបងអើយ នៅចុះប្អូនអើយកុំទុកម្នេញ
នៅឲ្យសុខាកុំកន្ទេញ បងឆាប់វិលវិញទេណាពៅ ។
នាងឮព្រះរៀមផ្ដាំដូច្នោះ ផ្អូកផ្អឹសកង់ពោះស្រស់ឆោមឆ្មៅ
ញាប់ញ័របំបប់ស្រស់ស្រណៅ នាងគង់នៃបនៅជិតមាតា ។
តាំងក្រុងអសុរព្រះបិតុរេត តាំងស្រេចទ្រាព្រះមាតា
ទ្រង់ព្រះកន្សែងថ្ងៃសោកា ទន្ទេញទន្ទេញថាមាសម្ដាយអើយ ។
កូនអើយថ្ងៃទៅកុំនៅយូរ ទ្រង់ម្ដាយគ្មានធូរដល់តិចឡើយ
អសុរបិតាចាស់ណាស់ហើយ កូនអើយប្រញាប់ឆាប់រួសរ៉ា ។
កុមារលាស្រេចតាំងពីព្រាណ បរចេញចាកបានផុតសេមា
ចូលក្នុងព្រៃព្រឹក្សទឹកខ្ញាបផ្សា ដល់ព្រះបិតាមាតាថ្ងៃ ។
ទឹកដល់នាងចន្ទបទុមា ម្លេះសមពុំស៊ាំទឹកស្រមយ៍
ដល់បងដឹងអើយណាមាសថ្លៃ ម្លេះសមសរសៃស្រស់ស្រែងទឹក ។
ណ្ហើយចុះប្អូនអើយយើងខំស្រូត ខំរូតដំណើរក្នុងព្រៃព្រឹក្ស
ឯចិត្តរៀមបងវែងរពុក ទឹកដល់នាងចន្ទបទុមា ។
ណាចិត្តមួយទឹកអ្នកម្ដាយ ឪពុកនៅឆ្ងាយណាប្រុសណា

ផុះបុះសង្កាតខំយាត្រា ឃើញមុខមាតាបិតាយើង ។
ប្អូនអើយខំស្រូតរូតដំណើរ ប្រុសអើយខំដើរបន្តិចឡើង
ឲ្យឆាប់បានដល់ទៅស្រុកយើង នឹងបានចុំ្កចើ្កងឪពុកម្តាយ ។
ទៅដល់កាលណាបក់កន្សែង ប្រាថ្នាឲ្យបានទ្រព្យសម្បាយ
មាសប្រាក់កែវកងធងទាំងឡាយ លើកជូនអ្នកម្តាយឪពុកយើង ។
កុមារទាំងពីរដើនតែដើរ គំនិតគិតធ្វើឲ្យរុងរឿង
ប្រញាប់សព្វគ្រប់ឲ្យមានឡើង ដំកុំដំកើងជូនមាតា ។
ហេតុតែបុព្វកម្មពីព្រេង ត្រូវឲ្យវង្វេងបែកបាកគ្នា
ព្រាត់ប្រាស់បងប្អូនក្នុងព្រឹក្សា កម្មតាមទាន់ណាក្នុងគ្រានេះ ។
ឯកុមារបងយកកន្សែង ប្រាថ្នាចង់បក់ឲ្យកើតសេះ
អស្សពាហ៍មួយមកគ្រាន់នឹងជិះ ជាយានជំនិះតទៅទៀត ។
បន្លាស្បូវស្រាតមុតបាទា ពុះពង់ខ្ញាបផ្កាក្នុងព្រៃញាត
ត្បូលក្នុងប្រកជ្រៅផ្លូវបង្អៀត ខំដើរទៅទៀតពុំរួចឡើយ ។
ទើបយកកន្សែងបក់មកណា កើតរូបអស្សពាហ៍ប្រាកដហើយ
ទើបបងឡើងជិះធ្វើព្រឺងើយ អនុជដើរក្រោយបន្តិចទៅ ។
ស្រាប់តែព្យុះខ្យល់មេឃងងឹត ពពកបាំងបិទមើលពុំយល់
ធ្លាក់ភ្លៀងខ្លោកៗ ជ្រុះមកដល់ កុមារប្រឹងរុលរត់តាមសេះ ។
កុមារប្រឹងរត់តាមពុំទាន់ គិតថាឪអញរអាម្មះ

ណាមួយព្រួយទឹងបាត់ដានសេះ　វាបោះតែលុនលឿនបាត់ទៅ ៗ
ព្រះសូរល្វើយ ៗ ខំកាត់រក　ជ្រៀតជ្រកគិតស្ម័គ្រហាក់មាត់ហៅ
មិនដឹងជាសត្វខំរត់ទៅ　ខំប្រឹងស្រែកហៅពុំព្រះឆ្លើយ ៗ
បងអើយ ៗ បងម្តេចបោលប្អូន　ជិះសេះបាត់សូន្យបោលប្អូនហើយ
ម្តេចមិនគិតប្អូនដល់តិចឡើយ　ឲ្យប្អូននៅក្រោយទឹងនរណា ៗ
មានតែដើមឈើនៅក្នុងព្រៃ　ខ្វាទឹងដំរីសឹងគជសា
ម្តេចហ៊ានះបាលប្អូនឲ្យវេទនា　កោតចិត្តរៀមរ៉ាមិនអាសូរ ៗ
រឿងប្អូនខ្ញុំស្ទះត្រឹមណោះសិន　ថ្លែងពីកុមារបងចាំយូរ
ត្រឡប់សេះវិញខំគិតគូរ　ថាប្អូនម្តេចយូរពុំឃើញមក ៗ
ស្រែកហៅថាអើយប្អូនអើយប្អូន　ម្តេចបាត់ឈឹងសូន្យបងខំរក
វង្វេងបាត់ដានបានមិនមក　ថ្ងៃអើយរកបងក្នុងស្ថានណា ៗ
ខំស្ទះស្វែងរកសព្វដងព្រៃ　ពុំឃើញឡើយនៃក្តួលនុរា
បណ្តូលបណ្តាប់មាសដ៏រ៉ា　កនិដ្ឋាម្តេចឡើយពុំឆ្លើយបង ៗ
ឱហេតុតែកម្មត្រូវទឹងព្រាត់　អំពើបងធ្វើឲ្យសោហ្មង
ឲ្យប្អូនឃ្លាតចាកចេញពីបង　ស្នេហ៍ស្នងម្ទុះសម្អកឃ្លានបាយ ៗ
លង់លុះព្រលប់យប់ស្ងាត់ឈឹង　កុមារខំប្រឹងរកខ្វល់ខ្វាយ
ព្រះតែសូរមាត់សត្វទាំងឡាយ　បៀរព្រៃយាបួលជ្រករកទ្រនំ ៗ
ទើបចុះពីលើខ្នងអស្សពាហ៍　បួលទៅនិទ្រាក្រោមឈើធំ

កូនជនព្រឹក្សព្រៃស្ងាត់ជ្រងំ ដោយចិត្តក្រៀមក្រមអាណិតប្អូន ។
ម្ដេះដេកកូនព្រៃតែម្នាក់ឯង ចម្លែងទឹកបងឈឺស្ងាត់សូន្យ
មិនដែលឃ្លាតបែកពីបងប្អូន ម្ដេះស្ងួនស្ងប់ស្ងាត់បាត់ស្មារតី ។
រឿងបងឈប់សេះប៉ុណ្ណោះសិន ខ្ញុំសូមថ្វាថ្លែងតាមសេចក្ដី
ពីអនុជប្អូននោះវិញនៃ ដេកនៅកូនព្រៃស្ងាត់សូន្យឈឹង ។
លុះដល់ព្រឹកព្រានព្រះសុរិយា ក្ដីបារម្ភស់ហើយណាកុមារប្រឹង
ត្រាច់ចរយាត្រាគិតរំពឹង កូនព្រៃស្រោងស្រឹងឥតមានស្រាកៗ
ត្រាច់ទៅត្រាច់មករកពុំឃើញ កូនព្រៃញាតសក្ដាតែលំបាក
ដើរតែម្នាក់ឯងវង្វេងគោកយ៉ាក បានផុតចេញចាកពីព្រៃធំ ។
បានចូលទៅដល់បុរីនគរ សេមាបវរដ្ឋចង្កុំ
ផុតពីស្រុកតូចចូលស្រុកធំ ចេញពីនិគមដល់ជនបទ ។
លុះបានទៅដល់ផ្ទះយាយចាស់ តាចាស់តាំងពីរពិតប្រាកដ
ដែលគាត់នៅកូនស្រុកជនបទ កំណត់នាយចក្ររុទ្ធទ្យានធន ។
ដល់ហើយលើកដៃឡើងសំពះ យាយតារួចស្រេចឥតមានហ្មង
ខ្ញុំសូមនៅនឹងលោកយាយផង ដោយខ្ញុំទ័លក្រលំបាក ។
យាយតាតាំងពីរអសោទរ មិនគិតពីក្ដីក្រគោកយ៉ាក
មិនគិតអត់ឃ្លានប្រឹងចាកពាក ដោយពាក្យចចារថាចៅអើយ ។
ចូរចៅឡើងមកនៅនឹងយាយ សព្វថ្ងៃគ្មានចៅនឹងគេឡើយ

បានពីរនាក់តាចៅឯងហើយ    ចៅអើយកុំឲ្យយាយស្ងាត់ពេក ។
កុមារនៅនឹងយាយតានោះ    លង់លុះឆ្នាំបីជាលង្វែក
ឥតមានទុក្ខភ័យអ្វីបំខ្យែក    មកបៀតបៀនកាយសប្បាយសុខ ។
ថ្លែងពីក្រុងសាកេតបុរី    ក្សត្រថ្ងៃសោយរាជ្យជាប្រមុខ
មហេសីបុត្រឥតមានទុក្ខ    គ្មានហេតុកលិយុគដល់នគរ ។
ទ្រង់នាមព្រះបាទសាមលរាជ    ព្រះអគ្គមហេសីស្រីសុន្ទរ
នាមរាជបុត្រីស្រីបវរ    មូលីសុន្ទររាជក្សត្រិយ៍ ។
ឆោមឆាយកាយឆើតកើតក្នុងភព    ល្អសព្វគ្មានទាស់ទំនាស់អ្វី
មានគ្រប់បញ្ចពិធកល្យាណី    ស្ត្រីគ្រប់លក្ខណ៍សក្តិសមប្រាណ ។
ល្អទាំងរូបភាទាំងដំណើរ    ល្អល្អះប្រសើរឥតប្រៀបបាន
ទ្រង់ព្រះយាងយាសក្នុងរាជស្ថាន    អត់ទ្រាំពុំបានមើលក្មេងខ្លួន ។
ឃើញវរក្សត្រិយ៍ស្រីទ្រង់ភ័ក្ត្រ    ល្អឯកឥតអាក់សក្តិសមសួន
អ្នកណាឃើញហើយសឹងភ្លេចខ្លួន    ជាប់ជួនសួនចិត្តឥតមានស្រាក ។
មានកាលសម័យថ្ងៃមួយណា    ចៅនឹងជីតានាំគ្នាចាក
ចេញពីផ្ទះទៅគ្មានសំរាក    ថែទាំសួនច្បារឧទ្យានហោង ។
ថ្លែងពីមូលីសុន្ទរស្រី    អផ្សុកព្រះទ័យពេកកន្លង
ចង់ទតសួនច្បារលេងបានម្តង    គិតស្រេចហើយហោងចរយាត្រា ។
ឡើងលើប្រាសាទប្រសើរខ្ពស់    លុតជង្គង់ចុះលើកហត្ថា

សូមទ្រង់បពិត្រព្រះបិតា    នឹងព្រះមាតាទាំងពីរពង្ស ៗ
កូនសូមក្រសាលលេងឧទ្យាន    កំសាន្តអផ្សុកទុក្ខក្នុងអង្គ
លេងក្នុងសួនច្បារអស់ចំណង់    ចុះស្រង់ក្នុងស្រះលេងសប្បាយ ៗ
ទើបស្ដេចត្រាស់ហៅពួកសេណីយ ឲ្យរៀបស្នំស្រីឆាប់ខ្វល់ខ្វាយ
ដង្ហែបុត្រីស្រីគបកាយ    កំសាន្តសប្បាយក្នុងសួនច្បារ ៗ
អមាត្យរៀបស្រេចក្រាបពិត្រទូល    បពិត្រឥស្សូរស្រេចហើយណា
សូមយាងព្រះនាងចេញយាត្រា    គង់លើវណាមាសប្រសើរ ៗ
ឡើងស្រេចព្រះនាងយាងចេញវៃ    ផុតពីវាំងជ័យស្រីស្នំដើរ
ដង្ហែមុខក្រោយដោយអើពើ    អមាត្យត្រួតមើលមុខក្រោយផង ៗ
ព្រះនាងយាងដល់ទីសួនច្បារ    ឃើញអង្គកុមារល្អកន្លង
ថែរទាំសួនច្បារស្អាតមង្ហាង    ល្អជាងសព្វដងគួរចង់មើល ៗ
ឃើញតានឹងហៅទៅជិតគ្នា    ទេវលេលាយាងដដើល
ត្រេចចរចូលជិតទស្សនាមើល    ចង់ព្រើលព្រឺព្រួចក្នុងចិត្ត ៗ
នាងមានសវនីយ៍ត្រាស់ទៅថា    នៃព្រះកុមារល្អពេកពិត
សួនច្បារនេះណាដូចនិមិត្ត    គួរឲ្យមានចិត្តរីករាយក្រៃ ៗ
ដូចជាទេវតាមកតែងទុក    មិនមែនទំនុកមនុស្សវិស័យ
ទេវតាតាំងទុកនៅក្នុងព្រៃ    គួរឲ្យសម័យជាប់ចិត្តពេក ៗ
ឯពួកស្រីស្នំក្រុមសេនា    យោធាច្រើនក្រៃជាអនេក

លេងក្នុងសួនឧទ្យានសប្បាយថ្ងៃក ដើរបែកបេះផ្កាលេងសប្បាយ ៗ
ខ្លះនាំគ្នាលេងពួនក្នុងព្រៃ ពាំងប្រុសពាំងស្រីលបលាក់កាយ
ក្រោយក្នុងគុម្ពផ្កាចិត្តរីករាយ ប្រុសពាល់ត្រូវកាយសម្ងំនៅ ៗ
ដោយមានតណ្ហាស្រេចស្រាលខ្លាំង វង្វេងក័ន្តកាំងក្មេងខុសត្រូវ
សប្បាយអស្ចារ្យក្នុងព្រៃជ្រៅ ក្មេងនាងស្រីពៅពាំងអស់គ្នា ៗ
ថ្ងៃនពីក្សត្រីយ៍ស្រីវរលក្ខណ៍ នាងមានចិត្តស្ម័គ្រនឹងកុមារ
ព្រះទ័យជាប់ចិត្តស្និទ្ធស្នេហា ជានៃលោកតានៅនេះចុះ ៗ
ខ្ញុំនាំកុមារលេងសប្បាយ ឲ្យបានស្រួលកាយកុមារនោះ
ចូលក្នុងសួនឧទ្យានផ្ការាយរុះ ខ្លះរីកស្គុលស្គុះជ្រុះព្រោងព្រាយ ៗ
ឯអង្គកុមារពុំដឹងខ្លួន ជានាងស្រីនួនប្រាថ្នាកាយ
នាំនាងទតផ្កាលេងសប្បាយ ពុំដឹងក្នុងកាយដល់តិចឡើយ ៗ
នាងនាំចូលក្នុងសួនឧទ្យានស្ងាត់ ថ្លល់ពាត់ខ្វែងខ្វាតចិត្តឥតស្បើយ
នាំអង្គកុមារលេងលំហើយ ស្រេចហើយចូលស្រង់ក្នុងស្រះស្រី
ឲ្យអង្គកុមារចូលស្រង់ផង មុជលេងលងល្បែងមេត្រី
នាងបាចសពៅកុមារខ្ចី មុចដេញស្រីថ្លៃនាងហែលពៅ ៗ
បាចសកុមារពីទឹករាក់ ដេញផ្ទាក់រហូតដល់ទឹកជ្រៅ
កុមារខំហាចហែលចូលពៅ ស្រីពៅប្រវាឧបកុមារ ៗ
ដោយសម្ផស្សស្រីក្តីសំរើប កុមារស្រៀវស្រើបក្នុងកាយា

នៅក្នុងស្រះស្រីរាវីថ្ងា គ្មានអ្នកឯណាជាពីរផង ៗ
រាគៈតណ្ហាបណ្ដាលឡើង ដោយក្ដីស្នេហាពេកកន្ទួង
ឡើងចាកពីស្រះស្រេចជាម្ដង ផ្លាស់ព័ស្ដ្រហើយហោងយាងចូលព្រៃ ៗ
ពីរនាក់នឹងអង្គវរកុមារ ដោយក្ដីស្នេហានាងស្រីថ្លៃ
ប្រកៀកប្រកិតកាយក្នុងព្រៃ ក្សត្រិយ៍នាងធ្វើជាអៀនអន់ ៗ
ចេញចាកពីព្រៃស្រីធីតា នឹងអង្គកុមារនេត្រាគន់
សំដៅកន្ទែងតាពីមុន ក្សត្រិយ៍តូចតន់ចាំពួកពល ៗ
លុះយូរបន្តិចពួកស្នំស្រី ត្រឡប់វិលវៃទាំងរេហ៍ពល
បរបួលមកជិតបង្គំគាល់ ក្សត្រិយ៍និមលគ្មានអន់អាក់ ៗ
ព្រះនាងមានព្រះវរវាចា នឹងពួកស្រីស្គាដោយស្មោះស្ម័គ្រ
លេងក្នុងសួនបុប្ផាផ្កាក្រងថ្នាក់ កម្រងមួយម្នាក់ពាក់គ្រប់ដៃ ៗ
សប្បាយណាស់បងទាំងអស់គ្នា ពេលខ្ញុំកំព្រានៅក្នុងព្រៃ
បានអង្គកុមារនឹងតាថ្លៃ កុំអីខ្ញុំតាមបងទៅហើយ ៗ
ខ្ញុំនឹកអាណិតបងគ្រប់គ្នា មិនធ្លាប់លេលាសប្បាយឡើយ
យើងលេងស្រះទៀតឃ្លាតជាត្រើយ ងូតទឹករួចហើយសឹមយាត្រា ៗ
ជម្រះមន្ទិលក្អួលសៅហ្មង ដែលកើតមានផងពីពៀសណា
យើងប្រឹងគ្រាប់លេងក្នុងព្រឹក្សា ស្រង់រាវីថ្ងាស្អាតប្រសើរ ៗ
ទេវីនាំអស់ស្នំបរិពារ ចុះស្រង់គត្ថាហែលលលលើ

នាំទាំងកុមារប្រុសប្រសើរ　　លលើហែលលេងសប្បាយចិត្ត ៗ
ដោយក្ដីស្នេហានាងទេវី　　នារីឲ្យអង្គកុមារស្និទ្ធ
ហិចហែលសសៀរចូលមកជិត　　វរមិត្រជិតដេញកុមារា ៗ
ឯពួកកក៏លៀងរៀងពល់ប្រាណ　　មុជលេងកំសាន្តសព្វកាយា
នូវពួកសេណីយនឹងសេនា　　សប្បាយគ្រប់គ្នាភ្ញាំងភ្លេចខ្លួន ៗ
ខ្លះបែងគ្នាលេងក្នុងទឹក　　ធ្វើបុកបែបជាមោលទៅពួន
ខ្លះហែលទៅជ្រកលបលាក់ខ្លួន　　បំពួនទឹងស្ទឹកកំពីងពួយ ៗ
ខ្លះមុជទៅឱបក្រសោបប្រាណ　　ចាប់បានរហូតដល់កាយស្ងួន
គីលៀងសប្បាយរៀងពល់ខ្លួន　　សមសួនដោយចិត្តស្និទ្ធមេត្រី ៗ
ខ្លះត្រេកត្រអាលទៅនឹងប្រុស　　មុជជ្រកនឹងគុម្ពចង្កលណី
បន្ទិចតែក្បាលហើយទះដៃ　　ប្រុសមុជប្រៀវប្រែសំដៅទៅ ៗ
ក្រសាវក្រសោបឱបប្រកិត　　កៀកកាយជួលជិតនិត្យនឹងនៅ
ដោយត្រេកត្រអាលក្នុងទឹកជ្រៅ　　បំបែរបៀតទៅគុម្ពត្រគៀត ៗ
ខ្លះស្នេហាពេកឱបពុំបាន　　យកដៃទៅប្រានត្រង់កន្ទៀត
ញៀក្បែរទៅជិតគុម្ពត្រគៀត　　ច្បាស់ភ្លៀតប្រលោមលោមស្រី ៗ ៗ
ត្រគៀតដូចបងក្រកង់ស្ងួន　　ត្រកួនដូចបងត្រកងបី
ព្រលិតដូចបងប្រលែងស្រី　　ចង្កលណីដូចបងចង់កល្យាណ ៗ
ឯពួកសេនានឹងសេណី　　នឹងអស់ស្ត្រីទាំងប៉ុន្មាន

នាំវរក្សត្រិយ៍ស្រង់កំសាន្ត ស្រេចបានឡើងចាកស្រះគង្គា ។
ទើបផ្លាស់ព្រះពស្ត្ររៀងរាល់ប្រាណ ក្សត្រិយ៍កល្យាណលាកុមារ
លាទាំងលោកតានាយសួនបុប្ផារ ចេញផុតហើយណាចូលរាំងវៃ ។
ដល់ថ្វាយបង្គំក្សត្រទ្វេហា បពិត្របិតាមាតាថ្លៃ
កូនសុំលាចេញទៅលេងព្រៃ សប្បាយពេកក្រៃឥតឧបមា ។
សូមទានឥតទោសសន្តោសខ្ញុំ មេត្តាសូមសុំព្រះករុណា
ទាំងពីរមាតានឹងបិតា សូមអត់ទោសខ្ញុំនៅក្មេង ។
ក្សត្រាទាំងពីរទ្រង់ត្រាស់ថា ព្រះទ័យករុណាគិតយល់ឈ្វេង
អាសូរកូនពេកពៅនៅក្មេង ចេះបរទាបែងថ្លែងសំដី ។
ណ្ហើយចុះកូនអើយយើងអត់ទោស យើងអត់អំណត់ចិត្តខន្តី
ទោះទោសតូចធំប៉ុន្មានក្តី កូនស្រីៗពុកអត់ទោសឲ្យ ។
រឿងនេះយើងស្ទះប៉ុណ្ណោះសិន មិនទាន់បរពាទុកខាងក្រោយ
ថ្ងៃពីកុមារនឹងតាហើយ បណ្តើររជយទៅឯផ្ទះ ។
ចំណែកខាងយាយចាំមើលផ្លូវ តាហើយនឹងចៅបាត់យូរណាស់
វល់ធ្វើអ្វីមិនមកផ្ទះ គិតណាស់តែចៅក្រែងឃ្លានបាយ ។
គំនិតយាយគិតតែប៉ុណ្ណោះ ក្រឡេកឃើញតាពីចម្ងាយ
មាត់សើចក្អាក ៗ ដៃដួសបាយ ថានៃចៅអើយញាំបាយទៅ ។
រឿងចៅនឹងយាយហើយនឹងតា យើងឈប់បរតាបង្អង់នៅ

ថ្លែងពីក្សត្រាព្រះចមទៅ ដែលស្ដេចគង់នៅក្នុងសេមា ៗ
ស្ដេចទ្រង់ប្រឈួនជាទម្ងន់ អាពាធឈឺធ្ងន់ពេកណាស់ណា
ទើបស្ដេចទ្រង់ថ្លែងព្រះឧង្ការ ត្រាស់ហៅសេនាទឹងសេណី ៗ
ត្រាស់ហៅអមាត្យពួកធំៗ មូលមកប្រជុំទឹងកុង្សីយ៍
ហៅទាំងសុន្ទរអគ្គមហាសី ហៅទាំងបុត្រីស្រីជីតា ៗ
មូលមកប្រជុំស្រេចជាម្ដង ក្សត្រាបញ្ចាស់ច្បងថ្លែងឧង្ការ
មន្ត្រីតូចធំទាំងអស់គ្នា ជួយថែរក្សាព្រះនគរ ៗ
ខ្ញុំឈឺម្ដងនេះគ្មានសង្ឃឹម ទេនែមហាសីស្រីសុន្ទរ
ថែកូនប្អូនថែទាំងនគរ ស្រីស្រស់បវរមកជិតបង ៗ
បងព្រាត់ពោលប្អូនថ្លៃទឹងហើយ សុន្ទរបងសូមអផ្អែលខ្លួន
ថែកូនឲ្យល្អណាមាសបង ថែមន្ត្រីផងឲ្យបានសុខ ៗ
នាងរក្សាចិត្តឲ្យបានល្អ បូរនាងយកធម៌មកតាំងទុក
ការល្អកុំធ្វើឲ្យអាក្រក់ បួលរក្សាទុកណាប្អូនស្រី ៗ
ទ្រង់មានបន្ទូលតែប៉ុណ្ណោះ ខ្យល់ដកហូតចុះអស់វិថី
សង្ខាររលត់ពេបខ្ចី វិថីរលត់ព្រមទាំងអស់ ៗ
ទៅតែមរណាវិថីមួយ នាំស្ងួយអណ្ដែតត្រៃសេតខ្ពស់
បង្កើតក្នុងស្ថានសួគ៌ឯណោះ ប្រាសាទខ្ពង់ខ្ពស់ប្រសើរក្រៃ ៗ
មហេសីបុត្រីទាំងពីរអង្គ សោយសោកខ្សឹកខ្សួលដោយអាល័យ

សោកទាំងនាម៉ឺនមុខមន្ត្រី    សេនាបតីកុង្ស៊ីយ៍ផង ៗ
ទើបលើកព្រះសពដាក់គោជមាស    បម្លាក់ពេញពាសល្អក្នុង
បូជាព្រះសពស្រេចជាម្ដង    គ្រប់គ្រងនគរសុន្ទរស្រី ៗ
ក្សត្រិយ៍ប្រជុំពួកនាម៉ឺន    គិតផ្សងរកអ្នកមានបារមី
បុស្សរថប្រសើរលើសហត្ថី    សម្បូរសព្វក្នុងខៀវផង ៗ
មន្ត្រីទាំងអស់យល់ព្រមព្រៀង    ឱង្ការព្រះនាងបន្ទូលផ្សង
ដល់ពួកទេវតាឥន្ទ្រព្រហ្មផង    សូមជួយបំណងបង់ប្រាថ្នា ៗ
បើអ្នកមានបុណ្យមានអំណាច    ត្រូវទឹងសោយរាជ្យព្រះសោមា
សាកេតបុរីនេះឯងណា    ឲ្យឃើញអស្ចារ្យទឹងដំរី ៗ
ទើបយកប្រដាប់សំរាប់រាជ្យ    សំរាប់ឡើងគង់ព្រះទែនថ្មី
លើកដាក់ទៅលើខ្នងហត្ថី    ដំរីបុស្សរថប្រសើរក្រៃ ៗ
ដំរីចេញផុតពីនគរ    សំដៅជនបទផ្ទះយាយតា
ដែលគាត់តែងធ្វើនាយសួនច្បារ    តែងថែរក្សាទៅមួយផង ៗ
ដំរីទៅដល់ថ្វាយបង្គំ    បរមកុមារស្រេចជាម្ដង
ពួកពលឃើញហើយអរកន្ទង    ថ្វាយបង្គំផងទាំងអស់គ្នា ៗ
ទើបយកប្រដាប់សំរាប់រាជ្យ    ទ្រង់ផ្លាស់ព្រះពស្ត្រាជកុមារ
ទើបយាងលើខ្នងគជេន្ទ្រ    បុស្សរថថ្ងៃថ្លាប្រសើរក្ដាត់ ៗ
ឲ្យតាយកខ្សែចងឯងផង    យាយយកដំបងវាយឯងថ្វាត់

ខ្ញុំយកទៅទុកកុំឲ្យបាត់ ប្រយ័ត្នក្រែងខានការពារខ្លួន ។
តាយាយខ្ញុំលាទៅសិនហើយ តាអើយថែយាយឲ្យមាំមួន
បើយាយនៅផ្ទះតាទៅសួន កុំប្រហែសខ្លួនយាយចាស់ហើយ ។
កុមារលាស្រេចបរិលវៃ ចូលកង្កាំងជ័យសេមាហើយ
ឯពួកមន្ត្រីហែមុខក្រោយ អរហើយសែនអរឥតឧបមា ។
នាម៉ឺនតូចធំមូលប្រជុំ ក្សត្រិយ៍ឧត្តមសុន្ទរណា
ឲ្យហៅបុត្រីស្រីកញ្ញា មូលីធីតាសុន្ទរផង ។
យើងគិតរៀបចំតាំងអភិសេក មូលីសុន្ទរធីតាហោង
ទឹងព្រះអនុជាសោយរាជ្យត្រង់ ដំណាងមាតាបិតាវិញ ។
តើអ្នកទាំងឡាយថាដូចម្ដេច ហ៊ឹនមុខមន្ត្រីអ្នកប្រាប់អញ
ទោះបីស្រឡាញ់មិនស្រឡាញ់ អ្នកប្រាប់ឲ្យអញខ្ញុំដឹងផង ។
មន្ត្រីតូចធំលើកអញ្ជលី ទូលព្រះទេវីដោយទំនង
ក្សត្រថ្លៃទាំងពីរល្អឥតហ្មង ល្មមលើកឲ្យគ្រងរាជ្យសេមា ។
នាម៉ឺនប្រជុំជំនុំស្រេច ព្រមទាំងសម្ដេចព្រះមាតា
ឲ្យព្រះរាជបុត្រទាំងពីរណា គ្រងព្រះភាពពជបុរី ។
រឿងនេះខ្ញុំស្ទះដោយសង្ខេប ពោលតាមបទបែបវែងពេកក្រៃ
សូមពោលដំណាតសេចក្ដី ពីព្រះរៀមថ្លៃចៅពលឯក ។
ជិះសេះរកប្អូនកង្កព្រឹកក្យា ពុំឃើញឡើយណាស្រក់ទឹកភ្នែក

តាំងយប់តាំងថ្ងៃពុំបានដេក
នឿយហត់ខ្លាំងពេកស្គមអស់ខ្លួន ។
លុះដើរទៅដល់បុរីនគរ
សោមាបវររដ្ឋប្រសើរ
ស្តេចមានបុណ្យខ្លាំងអំណាចលើ
លើសលប់ប្រសើរជាងស្តេចផង ។
ទ្រង់ព្រះនាមជាស្តេចព្រហ្មទត្ត
សោយរាជសម្បត្តិសម្បូណ៌ហោង
គ្រងពារាណសីធំកន្ទួង
ក្សត្រថ្លៃច្បាស់ច្បងមានមហេសី ។
ឯវរជាយាជាឯកអគ្គ
ព្រះនាមវររត្នរាជក្សត្រិយ៍
សុវណ្ណអម្ពរភ័ក្ត្រប្រិមប្រិយ៍
ប្រសើរលើសស្រីស្នំទាំងឡាយ ។
ស្តេចមានព្រះរាជបុត្រី
ស្រស់ស្រីរូបកើតឆើតឆោមឆាយ
ប្រសើរលើសលប់ស្រីទាំងឡាយ
រូបកាយប្រសើរស្មើស្រីសួគ៌ ។
ព្រះនាមសុវណ្ណអម្ពរស្រី
ភ័ក្ត្រស្រស់ប្រិមប្រិយ៍ដូចគំនូរ
ស្មើកិន្នរីបុត្រីសូរ
ល្អគ្មានប្រៀបផ្គួក្នុងលោកិយ ។
សោយរាជសម្បត្តិសុខសាន្តមក
មិនដែលមានហេតុគ្រោះថ្នាក់អ្វី
ស្រាប់តែពេលនេះព្រះបក្រី
ស្តេចទ្រង់អាពាធប្រឈួនធ្ងន់ ។
ទ្រង់ហៅមហេសីបុត្រីមក
ប្អូនអើយលែលកស្រស់ស្រីគន់
អាពាធបង់ឈឺកាន់តែធ្ងន់
ត្បូងគន់ថែទាំព្រះនគរ ។
ស្រាប់តែចាក់ដោតក្នុងទ្រូងបង
នួនល្អដូចជាកាំបិតគោរ
កាត់ក្នុងពោះវៀនធ្លាក់ចុះមក
ប្អូនអើយមើលឈាមក្រហមច្រាល ។
ហេតុតែកម្មបង់ពីបុរេ
វែកចង់បង់ធ្វើគេពីក្នុងកាល

មុនភ្ញាក់ឈាមមកក្រហមព្រាល    នេះគឺកម្មកាលតាមតាន់ហើយ ។
ប្អូនអើយស្រីកុំសោយសោកបង    នួនល្អងនាងកុំក្ដុកក្ដើយ
រក្សាទុកនៅឲ្យល្អហើយ    រក្សាកូនស្រីឲ្យបានសុខ ។
ប៉ុរប្អូនរក្សាមុខមន្ត្រី    គួបក្ដីដំក្ដីតាមដោយមុខ
នាងប្រឹងថែទាំឲ្យបានសុខ    ដំណាទៅមុខនាងបានស្រួល ។
ទ្រង់មានបន្ទូលផ្ដាំរួចស្រេច    កម្មបូលមកផ្ដាច់ដង្ហក់យោល
ពួកខ្យល់ទាំងអស់ប្រមូលមូល    ទទួលវង្គតពេលនោះឯង ។
នាងទ្រង់តាំងរៀបពិធីបុណ្យ    ប្រសើរវិសេសជាងជាក់ស្ដែង
ធ្វើមេមុណ្ឌបគ្រប់កន្លែង    ភ្លឺផ្លេកបិតែញ្ចចិញ្ចាចក្រៃ ។
ពីធីបុណ្យនេះច្រើនយ៉ាងណាស់    ខ្ញុំពោលកាត់ខ្លះកុំថាអ្វី
កុំឲ្យវែងពេកយូរកំរ៉ៃ    អ្នកអានសេចក្ដីនាំធុញទ្រាន់ ។
ប្រៀបដូចស៊ីស្ករផ្អែមច្រើនពេក    នាំឲ្យក្ដៅស្រែករអាល្ហាន់
សេចក្ដីវែងពេកនាំធុញទ្រាន់    តែល្ហាន់លែងចង់ស៊ីទៀតហើយ ។
សង្ខេបញយ ៗ មិនចេះចប់    សូមថែងកំណត់បទខាងក្រោយ
ពីទៅពលឯកបែកប្អូនហើយ    គ្រាក្រោយបានចូលដល់នគរ ។
ពាកណាសីនេះឯងណា    ខំប្រឹងយាត្រាមិនឈប់ឈរ
លុះដល់ទៀបទីព្រះនគរ    កុមារបវរបញ្ឈប់សេះ ។
នៅលើសាលាសំណាក់មួយ    កុមារតែងព្រួយគិតត្រិះរិះ

អញគិតដេកលើសាលានេះ　　លែងសេះឲ្យស៊ីស្មៅប្រញាប់ ។
ថ្ងៃពីទេវីពជក្សត្រីយ៍　　ធ្វើបុណ្យស្វាមីរួចស្រេចស្រាប់
ទ្រង់មានបន្ទូលត្រាស់បង្គាប់　　ឲ្យប្រាប់សេនាមាត្យមន្ត្រី ។
ជានៃនាហ្មឺនគ្រប់អង្គា　　ចូលនាំគ្នាជំនុំស្តី
យើងគិតរកស្តេចគ្រងបុរី　　អ្នកមានបារមីបុណ្យប្រសើរ ។
ទើបនាងឲ្យនាំដំរីមក　　បុស្សរថពទុកល្អលប់លើស
កុកទៀវអន្ទូងស្រស់ប្រសើរ　　មកដល់នាងធ្វើសច្ចាផ្សង ។
តាំងព្រាហ្មណ៍បារគូបុរោហិត　　លើកដៃអធិដ្ឋានជាម្តង
យើងខ្ញុំតាំងខ្លាយសូមបួងសួង　　ទេវតាព្រហ្មផងនឹងព្រះឥន្ទ្រ ។
លោកមានភ្នែកទិព្វត្រចៀកទិព្វ　　ដែលទ្រង់ព្រះនាមជាទេវិន្ទ្រ
សោយរាជ្យនៅក្នុងស្ថានព្រះឥន្ទ្រ　　ទ្រង់ជាអមរិន្ទ្រសហស្សន័យ ។
សូមចុះមកជួយជាសាក្សី　　ខ្ញុំផ្សងដំរីបុស្សរថថ្ងៃ
អ្នកណាមានបុណ្យបារមីក្រៃ　　សូមឲ្យដំរីថ្វាយបង្គំ ។
ផ្សងស្រេចនាងឲ្យលែងដំរី　　យាត្រាចេញខ្ចីសំដៅចំ
ដល់ព្រះកុមារថ្វាយបង្គំ　　កំពុងតែផ្ទុំលើសាលា ។
កុមារឡើងគង់លើដំរី　　ចាកសាលាខ្ចីចូលសេមា
ឯអគ្គសម្តេចព្រះមាតា　　អញ្ជើញកុមារឡើងប្រាសាទ ។
ប្រជុំនាហ្មឺនមុខមន្ត្រី　　ព្រមទាំងសេនីសេនាមាត្យ

នាងមានសវទិយ៍តទៅទៀត ថានៃអមាត្យផងគ្រប់គ្នា ៗ
ដ្បិតអីអគ្គព្រះកុមារនេះ មានបុណ្យបារមីជាអស្ចារ្យ
យើងគិតអភិសេកឯកពជា គ្រប់គ្រងភាពបុរីរដ្ឋ ៗ
ទឹងវរក្សត្រិយ៍ស្រីសុវណ្ណ អម្ពរសាក័ណជាក់ប្រាកដ
ជាមហេសីធំក្នុងរាជរដ្ឋ ប្រគល់សម្បត្តិពាភណសី ៗ
មន្ត្រីទាំងឡាយថាដូចម្ដេច ចូរអ្នកសម្រេចតាមសេចក្ដី
គំនិតរបស់ខ្ញុំជាស្រី ក្រែងស្ដីអាស្រូវត្រូវជួយគិត ៗ
បពិត្រក្សត្រិយ៍ថ្លៃប្រសើរ ដំណើរផលទ្រង់ព្រះរិះគិត
ជម្រិះបែបនេះឃើញត្រូវពិត តាមដោយសុចរិតបវេណី ៗ
ទើបនាងប្រគល់រាជសម្បត្តិ ក្រោមស្វេត្តច័ត្រលើមន្ទីរ
ឲ្យពរដល់បុត្រាជទាំងទ្វី ស្រោចទឹកកន្ទីក្រអូបសាយ ៗ
ទើបព្រាហ្មណ៍បារគូបុរោហិត លើកយកពាក្យពិតមកទំនាយ
សូមឲ្យក្សត្រាពីរព្រះកាយ សោយសុខសប្បាយព្រះជន្មវែង ៗ
ប្រទេសនានាសឹងគោតខ្លាច សូមឲ្យអំណាចខ្ពស់ចំពែង
សត្រូវជិតឆ្ងាយពីស្ដាំឆ្វេង សូមអស់រលីងរលត់ហោង ៗ
ព្រាហ្មណ៍ថ្វាយពរស្រេចកាលណា ហើយ ទាំងពីរក្សត្រិយ៍យាងចុះផ្គង
ចាកស្វេតច័ត្រស្រេចជាម្ដង ស្ដេចឡើងគង់លើប្រាសាទជ័យ ៗ
ចូលផ្ទុំនៃបនិត្យនឹងសុវណ្ណ អម្ពរសាក័ណក័ក្ដិប្រឹមប្រិយ

ដែលទើបអភិសេកបានថ្មោងថ្មី　　បក្រិជុំអែបនៃបនារី ៗ
ដោយពេញព្រះទ័យនឹងរូបឆោម　　ស្តេចទ្រង់ប្រលោមនាងទេវី
ព្រះទ័យស្មោះស្ម័គ្រនឹងទេពី　　ឥតមាននារីណាផ្ទឹមបាន ៗ
រីឯព្រះបាទឯកអគ្គប្ចើង　　តាំងទៀងសោយរាជ្យបានចុំថ្កាន
ល្បីឮរន្ទឺទៅសព្វស្ថាន　　ស្តេចមានសម្បត្តិពីរប្រការ ៗ
មានកន្ទ្រងបក់កន្ទ្រង់បោយ　　ស្តេចមានតាំងឆ្នាំងឆ្អិនឯងណា
ឮល្បីសម្បត្តិពីរប្រការ　　ដល់ស្តេចណាៗសឹងកោតខ្លាច ៗ
ឯស្តេចដទៃនាំសួយមក　　ថ្វាយក្សត្រពន្លកព្រោះអំណាច
គាន់តែឮឈ្មោះសឹងខ្លបខ្លាច　　ព្រោះព្រះអំណាចបញ្ញ័រផែនដី ៗ
នៅតែព្រះបាទអនុជា　　សោយរាជ្យនៅសាកេតបុរី
មិនខ្លាចអំណាចពារាណសី　　ដោយអាងបារមីបុទ្ធិចេស្តា ៗ
ដោយស្តេចមានខ្សែចងឯងផង　　មានតាំងដំបងវាយឯងណា
ល្បីល្បាញលើសលប់ភពលោកា　　គ្មានស្តេចឯណាហ៊ានប្រមាថ ៗ
រន្ទឺឮដល់ពារាណសី　　ឯកាចក្រីក្សត្រិយ៍នរនាថ
មិនឃើញសួយសាករថ្វាយទៀត　　តាមជាតិសាកេតកជបុរី ៗ
ទម្លាប់ធ្លាប់តែនាំថ្វាយ　　មកថ្វាយដល់ក្រុងពារាណសី
ឥឡូវបាត់សោះព្រោះហេតុអ្វី　　សាកេតបុរីមិនឃើញមក ៗ
ទើបត្រាស់ឲ្យហៅរាជទូតទ្វី　　អាល្បាក់ពីរបីទ្រង់ឲ្យយក

ក្រដាសទឹកខ្មៅសរសេរខ្នាក ទើបយកមកថ្វាយក្សត្រា ៗ
យើងជាព្រះចៅពារាណសី រាជទូតនាំទៅព្រះរាជសារ
ចុតហ្មាយឡាយព្រះហស្តលេខា ឲ្យស្តេចក្រុងសាកេតបុរី ៗ
នាំអស់សួយសាអាករមក ថ្វាយយើងឲ្យឆាប់ប្រញាប់ខ្មី
កុំពេលឥឡូវនេះឯងនែ ដល់ពារាណសីនគរយើង ៗ
បើធ្វើតាមរាជតម្រាស់នេះ សាកេតបុរីនឹងបានចម្រើន
បើស្តេចមិនធ្វើតាមសារយើង សាកេតបុរីវិនាសហើយ ៗ
បញ្ចប់រាជសារតែប៉ុណ្ណោះ អ្នកស្តេចគិតត្រិះកុំកន្តើយ
មិនទ្រង់តាមព្រះបង្គាប់ឡើយ នេះហើយទទឹងរាជឧង្ការ ៗ
ទូតយករាជសារដាក់ក្នុងស្រោម ស្តេចទ្រង់ប្រថាប់ព្រះសង្ហារ
ឈ្មោះអ្នកដទៃមិនត្រូវការ បើកព្រះសង្ហារត្រូវមានទោស ៗ
រាជទូតក្រាបថ្វាយបង្គំលា ចេញក្រៅសេមាបុរីនោះ
សំដៅនគរដែលចំណុះ នាមឈ្មោះសាកេតរាជបុរី ៗ
ដល់ហើយចូលក្រាបថ្វាយបង្គំ លើកហត្ថប្រណម្យដាក់សិរសី
ទូលថាសារនេះព្រះចក្រី ក្រុងពារាណសីនាំមកថ្វាយ ៗ
ទើបស្តេចទទួលរាជសារនោះ ហូតចេញពីស្រោមឆាប់ខ្វល់ខ្វាយ
ទ្រង់ទតរាជសារដោយពេះរាយ ស្តេចទ្រង់បានជ្រាបសព្វសេចក្តី ៗ
ទើបស្តេចឲ្យហៅអាឡក់មក ឲ្យយករាជសារមួយទៀតខ្មី

ថាយើងសាកេតរាជបុរី បក្រីព្រះនាមអនុជា ។
សព្វថ្ងៃត្រង់ឫទ្ធិនិងអំណាច យើងឥតមានខ្លាចស្តេចឯណា
បើពាកណាសីមានប្រាថ្នា ចង់បានសេមាសាកេតនេះ ។
ឲ្យចូលមកឆាប់ប្រញាប់ឡើង ព្រះបាទចុំបើងកុំវេរ
យើងអនុជាពុំសូវបេះ ដម្រេះអំពីខាងចម្បាំង ។
ស្តេចចូលមកចុះយើងឥតចុញ ឥតរាឥតរុញទឹងប្រណាំង
ឯត្រង់ពីខាងរឿងចម្បាំង យើងឥតក័ន្តកាំងខ្វបខ្លាចឡើយ ។
រាជទូតនាំសារត្រឡប់វិញ ដល់ពាកណាសីនគរហើយ
ថ្វាយសាដល់ក្សត្រាត្រាណត្រើយ ស្តេចទតសព្វហើយជ្រប់កក្រ្តា ។
ក្តៅអើយសែនក្តៅក្នុងព្រះទ័យ ដូចអគ្គិសនីឆេះខុព៉
ទើបលើកព្រះហស្តទះតុថា អាពោរមោហាព្រហើនក្រៃ ។
វគ្គមួយនេះឯងបែងចប់ហើយ ចម្បាំងខាងក្រោយវគ្គពីរនៃ
ចម្បាំងនោះធំណាស់ល្អស្តាប់ក្រៃ វគ្គមួយនេះនៃចប់ហើយហោង ។

ទីមួយ-ចប់

ពលឯកកុមារ-មាឥត

បម្បាំងទីពីរទៅទៀត

សូមជាវបន្ត ព្រោះរឿងខាងចុងពីរោះណាស់

រោងពុម្ពកុមារពាណិជ

លេខ ១៦ មហាវិថីឡេងសីសុវត្ថិ ភ្នំពេញ